# ព្រះរាជក្រឹត្យ

នស/រកត/១២០៨/១៤២៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ត្រាស់បង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

ត្រូវបានបង្កើត **"គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ"** ដែលមានឈ្មោះជាអក្សរកាត់ថា **"គ.ជ.អ.ប"** ដើម្បីសម្របសម្រួលដឹកនាំការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

## ជំពូកទី ២
## សមាសភាព និង បេសកកម្ម

**មាត្រា ២._**

គ.ជ.អ.ប មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៣- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងផែនការ | ជាសមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ជាសមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ជាសមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ជាសមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| ១២- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ជាសមាជិក |
| ១៣- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១រូប | ជាសមាជិក |
| ១៤- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប | ជាសមាជិក |
| ១៥- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ០១រូប | ជាសមាជិក |
| ១៦- ប្រធានលេខាធិការដ្ឋាននៃ គ.ជ.អ.ប | ជាសមាជិកអចិន្ត្រៃយ៍ |

ក្រៅពីសមាជិកខាងលើនេះ គ.ជ.អ.ប អាចស្នើបន្ថែមសមាជិកជារដ្ឋមន្ត្រី ឬប្រធានស្ថាប័ននៃក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល តាមការចាំបាច់។

សមាជិកម្នាក់ៗត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន គ.ជ.អ.ប។ ក្នុងករណីមិនអាចចូលរួមប្រជុំបាន សមាជិកនោះអាចតែងតាំងតំណាងមួយរូប ដែលជាសមាជិករាជរដ្ឋាភិបាល ដើម្បីជំនួសខ្លួននៅក្នុងការចូលរួមកិច្ចប្រជុំ ដោយធ្វើប្រតិភូកម្មអំណាចឱ្យតំណាងរូបនោះមានសិទ្ធិសម្រេចជំនួសខ្លួន។

គ.ជ.អ.ប អាចអញ្ជើញរដ្ឋមន្ត្រីក្រសួង ស្ថាប័ន ឬអាជ្ញាធរ ឬអ្នកពាក់ព័ន្ធផ្សេងៗទៀតឱ្យចូលរួមប្រជុំ ការពិភាក្សា ឬសហការការងារតាមការចាំបាច់។

**មាត្រា ៣.-**

គ.ជ.អ.ប មានបេសកកម្មសំខាន់ៗដូចខាងក្រោម ÷

- តាក់តែង និងអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

- ផ្អែកលើកម្មវិធីជាតិ គ.ជ.អ.ប ត្រូវរៀបចំផែនការសកម្មភាព និងគម្រោងថវិកាប្រចាំឆ្នាំ។

- ការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាពកម្មវិធីជាតិ ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ឱ្យបានសមស្រប។

- ពិគ្រោះ ពិភាក្សា សម្របសម្រួលជាមួយគ្រប់ក្រសួង ស្ថាប័នក្នុងការពិនិត្យមើលឡើងវិញនូវការទទួលខុសត្រូវ និងមុខងាររបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីកំណត់មុខងារ ការទទួលខុសត្រូវ សិទ្ធិអំណាច និងគណនេយ្យភាពសម្រាប់ផ្ទេរដល់ក្រុមប្រឹក្សានានានៅថ្នាក់ក្រោមជាតិ ដោយរួមជាមួយនឹង ÷

+ ការផ្ទេរធនធាន រួមមាន ចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និងសមត្ថភាព ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារនីមួយៗ។

+ ការផ្តល់លទ្ធភាព និងអំណាច ដើម្បីទទួលបានធនធានចាំបាច់រួមមានចំណូល ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ និងសមត្ថភាពសម្រាប់គ្រប់គ្រង និងអនុវត្តមុខងារនីមួយៗនោះ។

+ ការផ្តល់អំណាច និងភារកិច្ច ដើម្បីគ្រប់គ្រង និងអនុវត្តរាល់មុខងាររបស់ខ្លួនតាមគោលការណ៍ស្វ័យភាពមូលដ្ឋាន និងគណនេយ្យភាពនៅមូលដ្ឋានក្នុងកម្រិតជាអតិបរមា។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង

- ក្នុងពេលរង់ចាំការផ្ទេរមុខងារ និងការទទួលខុសត្រូវដល់ក្រុមប្រឹក្សានានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ គ.ជ.អ.ប ត្រូវកំណត់បែបបទ និងនីតិវិធីសម្រាប់ធ្វើសមាហរណកម្មនូវផែនការអភិវឌ្ឍន៍ និងថវិកានៃក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិទៅក្នុងផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រុមប្រឹក្សាតាមប្រភេទនីមួយៗ។

- អាចផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលអំពីការតាក់តែង ឬការធ្វើវិសោធនកម្មច្បាប់ ឬលិខិតបទដ្ឋាននានា ដើម្បីឱ្យស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

- ពិគ្រោះពិភាក្សា សម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានាតាមការចាំបាច់ ដើម្បីរៀបចំឱ្យមានរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការរៀបចំបែបបទ នីតិវិធីនៃការរៀបចំ ការអនុម័ត និងការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំប្រភពចំណូលរួមមាន ចំណូលពីថ្នាក់ជាតិ និងចំណូលនៅមូលដ្ឋាន ការផ្ទេរឧបត្ថម្ភថវិកា រួមមានមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ និងមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរទ្រព្យសម្បត្តិរដ្ឋ ការចាត់ចែង ការគ្រប់គ្រង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដែលប្រគល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯង ដោយមានផែនការជាជំហានៗ មានសង្គតិភាព មានការសម្របសម្រួល មានការពិគ្រោះយោបល់ មានតម្លាភាព និងមានគណនេយ្យភាព។

- សហការជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដើម្បីកំណត់គោលនយោបាយយុទ្ធសាស្ត្រសម្រាប់ការពិនិត្យ និងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក ស្របពេលជាមួយនឹងការផ្ទេរមុខងារ និងការទទួលខុសត្រូវ ក្នុងគោលបំណងបង្កើតឱ្យមានក្របខ័ណ្ឌបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅតាមរបៀបដែលមានផែនការ មានកម្មវិធី មានសង្គតិភាព មានការពិគ្រោះយោបល់ និងមានតម្លាភាព។

- កំណត់អំពីប្រភេទបុគ្គលិកសម្រាប់ប្រភេទក្រុមប្រឹក្សានីមួយៗ និងកំណត់អំពីរបៀប និងគោលនយោបាយក្នុងការកែសម្រួលឡើងវិញនូវការរៀបចំបុគ្គលិក ដោយធានាមិនឱ្យមានការបង្កើនចំនួនបុគ្គលិកសាធារណៈ។

- សហការជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធតាមការចាំបាច់ ដើម្បីរៀបចំសេចក្តីព្រាងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

- ត្រូវធានាឱ្យមានការសម្របសម្រួល និងពិគ្រោះយោបល់អំពីគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់នានាដែលអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធនានាដើម្បីឱ្យមានសង្គតិភាពជាមួយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងកម្មវិធីជាតិ។

- សិក្សាស្រាវជ្រាវ និងកំណត់ឡើងវិញនូវព្រំប្រទល់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិតាមការចាំបាច់។

- សិក្សាស្រាវជ្រាវអំពីកំណើនទីក្រុង និងនគរូបនីយកម្ម សម្រាប់ជាមូលដ្ឋានបង្កើតនូវគោលនយោបាយ រចនាសម្ព័ន្ធ និងយុទ្ធសាស្ត្រគ្រប់គ្រងទីក្រុងឱ្យបានសមស្រប។

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ សម្រាប់កសាងសមត្ថភាពក្រុមប្រឹក្សា និងរដ្ឋបាលរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ។

- សហការសិក្សាស្រាវជ្រាវ និងផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាល ក្នុងការបង្កើតនូវមូលនិធិសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដ៏សមស្របមួយ ដើម្បីប្រមូលផ្តុំប្រភពធនធានពីដៃគូអភិវឌ្ឍន៍នានាសម្រាប់តម្រូវការផ្នែកបុគ្គលិក និងកិច្ចសហប្រតិបត្តិការការអភិវឌ្ឍន៍ ការគាំទ្រផ្នែកបច្ចេកទេស និងតម្រូវការចាំបាច់នានានៅថ្នាក់ក្រោមជាតិ ព្រមទាំងការផ្តល់ជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

- ស្រាវជ្រាវ ពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលអំពីទម្រង់សម្រាប់កៀរគរ និងប្រើប្រាស់ធនធាននៅក្នុង និងក្រៅប្រទេស សម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

- ស្រាវជ្រាវ និងរៀបចំនូវកិច្ចព្រមព្រៀងមួយរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាឱ្យដៃគូអភិវឌ្ឍន៍ទាំងអស់ជាភាគីនៃកិច្ចព្រមព្រៀងនេះ ដែលជាការធានានូវការតម្រឹម និងសុខដុមនីយកម្មក្នុងការប្រើប្រាស់ជំនួយ។

- បង្កើតនូវវេទិកាដ៏សមស្របមួយរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានាសម្រាប់សម្របសម្រួលកិច្ចសហប្រតិបត្តិការ និងការគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

- ធានាឱ្យមានការផ្ទេរសិទ្ធិ និងការទទួលខុសត្រូវពីរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ បច្ចុប្បន្នទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលបានបង្កើត ស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

- ធ្វើសេចក្ដីរាយការណ៍ជូនរាជរដ្ឋាភិបាលរៀងរាល់មួយឆ្នាំម្ដង អំពីការអនុវត្តច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

- បំពេញការងារផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល។

## ជំពូកទី ៣
## អំពីការទទួលខុសត្រូវ និងសិទ្ធិអំណាច

**មាត្រា ៤.-**

គ.ជ.អ.ប មានការទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល អំពីការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

**មាត្រា ៥.-**

គ.ជ.អ.ប ត្រូវធានាឱ្យច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវបានអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធនានា នៅថ្នាក់ជាតិ មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា ៦.-**

គ.ជ.អ.ប ត្រូវធានាឱ្យគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់នានាមានសង្គតិភាពជាមួយច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

**មាត្រា ៧.-**

គ.ជ.អ.ប អាចដោះស្រាយ ឬលើកសំណើសុំសេចក្ដីសម្រេចពីរាជរដ្ឋាភិបាលលើការមិនចុះសម្រុងគ្នា ដែលអាចកើតមានឡើងទាក់ទងនឹងការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

មាត្រា ៨.-

អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល មន្ទីរ អង្គភាពនានា និងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចអនុវត្តសេចក្តីសម្រេចរបស់ គ.ជ.អ.ប។

មាត្រា ៩.-

ករណីក្រសួង ស្ថាប័នណាមួយរបស់រាជរដ្ឋាភិបាល មិនអនុវត្តតាមការសម្រេចរបស់ គ.ជ.អ.ប គណៈកម្មាធិការជាតិត្រូវរាយការណ៍ ដើម្បីសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

មាត្រា ១០.-

ករណីក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ មិនអនុវត្តតាមការសម្រេចរបស់ គ.ជ.អ.ប គណៈកម្មាធិការជាតិ ត្រូវស្នើដល់ក្រសួងមហាផ្ទៃដើម្បីអនុវត្តទៅតាមនីតិវិធីដែលបានកំណត់ក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

មាត្រា ១១.-

គ.ជ.អ.ប ត្រូវមានសញ្ញាសម្គាល់ និងមានត្រារបស់ខ្លួនដែលកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ គ.ជ.អ.ប។

## ជំពូកទី ៤
## របៀបរបបការងារ រចនាសម្ព័ន្ធ និងលេខាធិការដ្ឋាន

មាត្រា ១២.-

គ.ជ.អ.ប ត្រូវជួបប្រជុំសាមញ្ញរៀងរាល់ពីរ(០២)ខែម្តង។

គ.ជ.អ.ប អាចធ្វើការប្រជុំវិសាមញ្ញតាមការចាំបាច់ តាមការស្នើសុំរបស់ប្រធាន ឬ សមាជិកយ៉ាងតិច១ភាគ៣ នៃសមាជិកទាំងមូលរបស់ គ.ជ.អ.ប។

គ.ជ.អ.ប ត្រូវរៀបចំ និងអនុម័តនូវរបៀបរបបការងារ និងបទបញ្ជាផ្ទៃក្នុងនៅក្នុងកិច្ចប្រជុំលើកទី១របស់ខ្លួន ។

មាត្រា ១៣.-

ត្រូវបង្កើតអនុគណៈកម្មាធិការ ដើម្បីធ្វើជាជំនួយការឱ្យ គ.ជ.អ.ប ដែលមានដូចខាងក្រោម៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



/12

- អនុគណៈកម្មាធិការមុខងារ និងធនធាន
- អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ
- អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រៅពីអនុគណៈកម្មាធិការទាំងបី(០៣)ខាងលើ គ.ជ.អ.ប អាចស្នើសុំបង្កើតអនុគណៈកម្មាធិការផ្សេងៗទៀតជាជំនួយការ តាមការចាំបាច់។

**មាត្រា ១៤.-**

អនុគណៈកម្មាធិការនីមួយៗ ត្រូវដឹកនាំដោយប្រធានមួយ(០១)រូប អមដោយអនុប្រធានចំនួនពីរ(០២)រូប។

សមាសភាពអនុគណៈកម្មាធិការនៃ គ.ជ.អ.ប ព្រមទាំងរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការនីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ គ.ជ.អ.ប។

**មាត្រា ១៥.-**

អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល ឬ/និង អ្នកពាក់ព័ន្ធនានាមុនពេលផ្តល់អនុសាសន៍ដល់ គ.ជ.អ.ប។

**មាត្រា ១៦.-**

អនុគណៈកម្មាធិការនីមួយៗ អាចបង្កើតក្រុមការងារមួយ ឬច្រើនតាមការចាំបាច់ ដើម្បីសិក្សា និងរាយការណ៍អំពីការងារដែលស្ថិតនៅក្នុងភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន។ សមាជិកនៃក្រុមការងារនេះ អាចជ្រើសរើសចេញពីមន្ត្រីក្រសួង ស្ថាប័ននៃប្រធានអនុគណៈកម្មាធិការនោះ ឬអាចស្នើសុំមន្ត្រីពីក្រសួង ស្ថាប័នដែលមានតំណាងក្នុងអនុគណៈកម្មាធិការ ឬ/និង តំណាងពីអ្នកពាក់ព័ន្ធនានាតាមការសម្រេចរបស់អនុគណៈកម្មាធិការ។

**មាត្រា ១៧.-**

ក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវបង្កើតឱ្យមានក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការប្រចាំក្រសួង ស្ថាប័នខ្លួន ដើម្បីសម្របសម្រួល និងគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

គ.ជ.អ.ប អាចចេញសេចក្តីណែនាំអំពីកិច្ចដំណើរការនៃក្រុមការងារខាងលើនេះ តាមការចាំបាច់។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

មាត្រា ១៨.-

គ.ជ.អ.ប ត្រូវមានលេខាធិការដ្ឋានមួយស្ថិតនៅក្នុងទីស្តីការក្រសួងមហាផ្ទៃ។

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវដឹកនាំដោយប្រធានមួយ(០១)រូប ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ អមដោយអនុប្រធានចំនួនបី(០៣)រូប ដែលមានឋានៈស្មើអគ្គនាយកជាជំនួយការ ដែលតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមរយៈសេចក្តីស្នើសុំពី គ.ជ.អ.ប។

លេខាធិការដ្ឋានត្រូវបង្កើតឱ្យមានអង្គភាពនានាដែលកំណត់ដោយអនុក្រឹត្យ។

អង្គភាពនីមួយៗនៃលេខាធិការដ្ឋាន ត្រូវគ្រប់គ្រងដោយប្រធាន ០១រូប និងអនុប្រធានមួយចំនួនជាជំនួយការដែលតែងតាំងដោយអនុក្រឹត្យ។

ប្រធានអង្គភាពត្រូវមានឋានៈស្មើអគ្គនាយករង អនុប្រធានអង្គភាពត្រូវមានឋានៈស្មើប្រធាននាយកដ្ឋាន។

មាត្រា ១៩.-

លេខាធិការដ្ឋាន ត្រូវបំពេញរាល់កិច្ចការចាំបាច់នានា ដើម្បីធានាឱ្យ គ.ជ.អ.ប បំពេញមុខងាររបស់ខ្លួនបានសមស្រប និងមានប្រសិទ្ធភាព ព្រមទាំងជួយជាជំនួយបច្ចេកទេស និងលេខាធិការដល់អនុគណៈកម្មាធិការនីមួយៗ។

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ គ.ជ.អ.ប ។

## ជំពូកទី ៥
## ប្រភពធនធានថវិកា

មាត្រា ២០.-

គ.ជ.អ.ប ត្រូវមានថវិការបស់ខ្លួន ដើម្បីបំពេញការងារដែលសមស្របនឹងតម្រូវការនានាដែលមានចែងនៅក្នុងកម្មវិធីជាតិ និងតម្រូវការនានាសម្រាប់អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

ថវិការបស់ គ.ជ.អ.ប ត្រូវស្ថិតក្នុងខ្ទង់មួយដោយឡែក ក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ២១.-**

គ.ជ.អ.ប អាចទទួលជំនួយផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងសម្ភារៈពីប្រភពក្នុងប្រទេស និងក្រៅប្រទេស សម្រាប់អនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**មាត្រា ២២.-**

ក្នុងរយៈពេលដែលមិនទាន់មានលេខាធិការដ្ឋាននៃ គ.ជ.អ.ប តាមស្មារតីនៃព្រះរាជក្រឹត្យនេះ លេខាធិការដ្ឋាននៃ គ.ជ.រ.វ ត្រូវបន្តការងារជាលេខាធិការដ្ឋាននៃ គ.ជ.អ.ប។

**មាត្រា ២៣.-**

គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង និងគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ត្រូវបន្តធ្វើជារចនាសម្ព័ន្ធ និងប្រព័ន្ធគាំទ្ររបស់គ.ជ.អ.ប នៅរដ្ឋបាលថ្នាក់ក្រោមជាតិរហូតដល់មានការរៀបចំជាថ្មី។

**មាត្រា ២៤.-**

រាល់កិច្ចការដែលសេសសល់ពី គ.ជ.រ.វ រួមទាំងសេចក្ដីសម្រេចនានា ផែនការសកម្មភាព និងថវិកា គម្រោង កម្មវិធី និងកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា គ.ជ.អ.ប ត្រូវបន្តសម្របសម្រួលអនុវត្តអោយបានសមស្រប និងមានប្រសិទ្ធភាព។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**មាត្រា ២៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

មាត្រា ២៦.-

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសមាសភាពដូចមានចែងក្នុងមាត្រា ២ខាងលើ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨

៣រល.០៤១២.១៤៤៩ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ០៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី.១៦ ខែមករា ឆ្នាំ២០០៩

**អគ្គលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី**

**ឃុន ជិនកេន**